សប្តាហ៍ទី 19

រឿងសាំសុន

ព្រះជាម្ចាស់គង់ជាមួយសាំសុន

រឿងក្នុងព្រះគម្ពីរ

សាំសុនជាបុរសដែលបានកម្លាំងខ្លាំងណាស់។ អាថ៌កំបាំងនៃកម្លាំងរបស់គាត់គឺជាសក់របស់គាត់។ ពេលព្រះជាម្ចាស់គង់ជាមួយសាំសុន គាត់អាចធ្វើអ្វីៗបានគ្រប់យ៉ាង។ ទោះជាយ៉ាងណាក៏ដោយ ពេលមួយដែលសាំសុនបានចាកចេញពីព្រះជាម្ចាស់ ហើយជួបជាមួយមិត្តភក្តិដ៏អាក្រក់ សក់របស់គាត់ត្រូវបានគេកាត់ ហើយគាត់បានបាត់បង់កម្លាំង។

សាំសុនបានអធិស្ឋានទៅព្រះជាម្ចាស់ម្តងទៀត ដើម្បីសុំជំនួយ។ ព្រះជាម្ចាស់បានឮការអធិស្ឋានរបស់សាំសុន ហើយបានផ្តល់កម្លាំងដល់គាត់ជាថ្មីម្តងទៀត!

ពេលដែលពួកយើងនៅជាមួយព្រះជាម្ចាស់ ពួកយើងអាចយកឈ្នះរាល់ទាំងការលំបាក។

សមិទ្ធផលសម្រេច



ពេលព្រះជាម្ចាស់គង់នៅជាមួយសាំសុន
គាត់អាចធ្វើអ្វីៗបានគ្រប់យ៉ាង!

វត្ថុបំណង

- ស្តាប់ និងយល់ដឹងពីរឿងរបស់សាំសុនដែលព្រះជាម្ចាស់គង់នៅជាមួយគាត់។
- សិក្សាពីរបៀបប្រើប្រាស់អេប៉ុងដើម្បីបង្កើតផ្ទៃខាងក្រោយ។
- បញ្ចប់រូបរបស់សាំសុនដោយប្រើរូបភាពស្រមោល។
- អភិវឌ្ឍគំនិរច្នៃប្រឌិត និងបញ្ចេញតាមរយៈសិល្បៈហត្ថកម្ម។

សម្ភារៈ



របៀបធ្វើ

1. រៀបចំផ្ទៃខាងក្រោយ



លាតក្រដាសផ្តេកឱ្យរាបស្មើ ហើយជ្រើសរើសពណ៌សម្រាប់ផ្ទាំងខាងក្រោយ។

2. ផ្តិតពណ៌ដោយអេប៉ុង (មេឃ)



ជ្រលក់អេប៉ុងក្នុងទឹកពណ៌ ហើយផ្តិចថ្នមលើផ្នែកខាងលើនៃក្រដាស។ (ពណ៌ចាស់ទៅពណ៌ស្រាស)

3. ផ្តិតពណ៌ដោយអេប៉ុង (ថ្ងៃលិច)



ប្រើពណ៌ផ្សេងទៀតដើម្បីធ្វើថ្ងៃលិច។ លាយពណ៌បញ្ចូលគ្នាតាមបែបធម្មជាតិ។

4. បញ្ចប់ផ្ទៃខាងក្រោយ



សូមឱ្យទឹកថ្នាំស្ងួតសិន មុនចាប់ផ្តើមជំហានបន្ទាប់។

5. បង្កើតរូបភាពស្រមោលសាំសុន



កាត់រូបភាពស្រមើលសាំសុនចេញពីក្រដាសកាតុងពណ៌ខ្មៅ។ (អ្នកអាចគូររូបរាងដោយខ្លួនឯង)

6. ការបញ្ចប់



បិទការ៉ូបសាំសុននៅលើផ្ទៃខាងក្រោយ ហើយបិទភ្ជាប់សសរ។ ស្នាដៃឯករបស់អ្នកបានបញ្ចប់!

Tip សម្រាប់លេង

- និយាយពីមូលហេតុដែលសាំសុនបាត់បង់កម្លាំង។
- ចែករំលែកពីរបៀបដែលព្រះជាម្ចាស់ជួយសាំសុនម្តងទៀត។
- ដាក់តាំងស្នាដៃហត្ថកម្មនៅក្នុងថ្នាក់រៀន ឬនៅផ្ទះ។
- មើលទៅកិច្ចការរបស់មិត្តភក្តិ ហើយផ្តល់មតិដោយសេចក្តីសប្បុរសលើសិល្បៈហត្ថកម្មរបស់គេ។



Tip សម្រាប់គ្រូ

- សូមប្រើទឹកពណ៌តិចៗលើអេប៉ុង ដើម្បីចេញពណ៌ស្រាលល្អ។
- សូមណែនាំកុមារឱ្យចេះលាយទឹកពណ៌ពីពណ៌ចាស់ទៅពណ៌ស្រាស។
- សូមរៀបចំគំនូសព្រាងស្រមោលទុកជាមុនសម្រាប់កុមារតូចៗ។
- សូមលើកទឹកចិត្តកុមារឱ្យជ្រើសរើសពណ៌ដោយសេរី។
- និយាយរួមគ្នា "ពេលខ្ញុំនៅជាមួយព្រះជាម្ចាស់ ខ្ញុំអាចមានកម្លាំងខ្លាំង!" រួចបញ្ចប់សកម្មភាព។